KAISER PERMANENTE

# សេចក្តីសង្ខេបអំពីគោលការណ៍ជំនួយហិរញ្ញវត្ថុផ្នែកវេជ្ជសាស្ត្រ

កម្មវិធីជំនួយហិរញ្ញវត្ថុផ្នែកវេជ្ជសាស្ត្ររបស់ Kaiser Permanente (Kaiser Permanente's Medical Financial Assistance, MFA) ផ្តល់ជំនួយហិរញ្ញវត្ថុសម្រាប់អ្នកជំងឺដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលត្រូវការជំនួយក្នុងការទូទាត់ប្រាក់សម្រាប់ការសង្គ្រោះបន្ទាន់ ឬការថែទាំចាំបាច់ផ្នែកវេជ្ជសាស្ត្រដែលពួកគេទទួលបាននៅក្នុងទីតាំងរបស់ Kaiser Permanente ឬដោយអ្នកផ្តល់សេវារបស់ Kaiser Permanete។ អ្នកជំងឺអាចដាក់ពាក្យសុំសម្រាប់កម្មវិធី MFA តាមវិធីជាច្រើនដែលរួមមាន តាមអនឡាញ ដោយផ្ទាល់ តាមទូរស័ព្ទ ឬដោយការបំពេញនិងដាក់ជូន ឯកសារពាក្យសុំ។ អ្នកជំងឺត្រូវតែបំពេញបានតាមល័ក្ខខ័ណ្ឌតម្រូវសិទ្ធិទទួលបានដូចខាងក្រោមដើម្បីមានសិទ្ធិ។

**តើនរណាខ្លះមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុ ហើយតើល័ក្ខខ័ណ្ឌតម្រូវមានអ្វីខ្លះ?**
កម្មវិធីនេះជួយអ្នកជំងឺដែលមានប្រាក់ចំណូលទាប ដែលមិនមានធានារ៉ាប់រង ឬមិនត្រូវបានបម្រើសេវាគ្រប់គ្រាន់ដែលត្រូវការជំនួយក្នុងការទូទាត់ប្រាក់ទាំងអស់ ឬមួយផ្នែកនៃការថែទាំវេជ្ជសាស្ត្ររបស់ពួកគេ។ ជាទូទៅ អ្នកជំងឺមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុនៅពេលដែលប្រាក់ចំណូលក្នុងគ្រួសារសរុបរបស់ពួកគេស្ថិតនៅត្រឹម ឬក្រោម 400% នៃសេចក្តីណែនាំកម្រិតភាពក្រីក្រនៃសហព័ន្ធ (Federal Poverty Guidelines, FPG) ឬមានការចំណាយផ្នែកវេជ្ជសាស្ត្រខ្ពស់ខុសពីធម្មតា។ អ្នកជំងឺគួរតែនិយាយជាមួយអ្នកប្រឹក្សាហិរញ្ញវត្ថុដើម្បីកំណត់សិទ្ធិទទួលបាន និងសម្រាប់ជំនួយក្នុងការដាក់ពាក្យ។

*អ្នកជំងឺដែលមានសិទ្ធិទទួលជំនួយហិរញ្ញវត្ថុវេជ្ជសាស្ត្រមិនត្រូវបានគិតថ្លៃច្រើនជាងចំនួនទឹកប្រាក់ ដែលត្រូវបានចេញវិក័យប័ត្រជាទូទៅ (AGB) សម្រាប់ការថែទាំសង្គ្រោះបន្ទាន់ ឬការថែទាំចាំបាច់ផ្នែកវេជ្ជសាស្ត្រដទៃទៀតទេ។ សូមមើល kp.org/mfa/nw សម្រាប់ព័ត៌មានអំពី AGB។*

**តើ Kaiser Permanente ពិនិត្យជ្រើសរើសអ្នកជំងឺសម្រាប់សិទ្ធិទទួលបានកម្មវិធីសាធារណៈនិងឯកជនដែរឬទេ?**
Kaiser Permanente ផ្តល់ដល់អ្នកជំងឺនូវជំនួយដើម្បីកំណត់កម្មវិធីធានារ៉ាប់រងសុខភាពសាធារណៈ និងឯកជនមានសក្តានុពលដែលអាចជួយដល់តម្រូវការនានានៃទទួលបានការថែទាំសុខភាព។ អ្នកជំងឺដែលត្រូវបានសន្មតថាមានសិទ្ធិទទួលបានកម្មវិធីរ៉ាប់រងសុខភាពសាធារណៈឬឯកជនណាមួយ នឹងត្រូវបានតម្រូវឲ្យដាក់ពាក្យសុំកម្មវិធីទាំងនោះ។

**តើកម្មវិធីរ៉ាប់រងលើអ្វីខ្លះ?**
កម្មវិធីជំនួយហិរញ្ញវត្ថុវេជ្ជសាស្ត្ររ៉ាប់រងទាំងអស់ ឬមួយផ្នែកនៃការថែទាំចាំបាច់ផ្នែកវេជ្ជសាស្ត្រ ដែលត្រូវបានផ្តល់នៅឯការិយាល័យវេជ្ជសាស្ត្រ Kaiser Permanente មន្ទីរពេទ្យ ឱសថស្ថាន ឬត្រូវបានផ្តល់ដោយអ្នកផ្តល់សេវារបស់ Kaiser Permanente។ ប្រភេទនៃសេវាកម្មដែលមិនត្រូវបានរ៉ាប់រងរួមមាន សេវាកម្មដែលមិនត្រូវបានចាត់ទុកជាការសង្គ្រោះបន្ទាន់ ឬចាំបាច់ផ្នែកវេជ្ជសាស្ត្រដោយអ្នកផ្តល់សេវារបស់ Kaiser Permanente ការព្យាបាលភាពមិនអាចបង្កកំណើតបាននិងការពពោះបង្កើតកូនជំនួស ក៏ដូចជាការបង់ប្រាក់បុព្វលាភការថែទាំសុខភាពផងដែរ។ សូមមើលបញ្ជីពេញលេញបន្ថែមនៅក្នុងគោលការណ៍ MFA។

**តើមានជំនួយផ្នែកភាសាដែរឬទេ?**
អ្នកបកប្រែអាចរកបានសម្រាប់អ្នកដោយឥតគិតថ្លៃ។ ពាក្យសុំជំនួយហិរញ្ញវត្ថុវេជ្ជសាស្ត្រ គោលការណ៍ និងសេចក្តីសង្ខេបគោលការណ៍នេះអាចរកបានជាភាសារបស់អ្នក។ សម្រាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅ 800-324-8010 ឬចូលទៅកាន់គេហទំព័ររបស់ពួកយើងនៅ kp.org/mfa.nw។

**តើ Kaiser Permanente មានគោលការណ៍ជំនួយហិរញ្ញវត្ថុវេជ្ជសាស្ត្រដែរឬទេ?**
អ្នកអាចស្នើសុំច្បាប់ចម្លងឥតគិតថ្លៃរបស់អ្នកនៃគោលការណ៍ជំនួយហិរញ្ញវត្ថុវេជ្ជសាស្ត្ររបស់ Kaiser Permanente (Kaiser Permanente's Medical Financial Assistance) ដោយទូរស័ព្ទទៅ 800-813-2000 ឬផ្ញើរសំបុត្រទៅ 500 NE Multnomah Street, Suite 100, Portland, OR 97232 ឬចូលទៅកាន់គេហទំព័ររបស់ពួកយើងនៅ kp.org/mfa/nw។

**ត្រូវការជំនួយឬ?**
សម្រាប់ជំនួយឬសំណួរអំពីដំណើរការដាក់ពាក្យសុំជំនួយហិរញ្ញវត្ថុវេជ្ជសាស្ត្រ សូមទូរស័ព្ទទៅ ឬនិយាយទៅកាន់អ្នកប្រឹក្សាហិរញ្ញវត្ថុដែលនៅក្បែរនាយកដ្ឋានសេវាកម្មកិច្ចការទទួលបានរបស់អ្នកជំងឺ (Patient Access Business Services Department) នៅឯមន្ទីរពេទ្យ Kaiser Permanente ។

**តើខ្ញុំដាក់ពាក្យសុំដោយរបៀបណា?**
អ្នកអាចដាក់ពាក្យសុំជំនួយហិរញ្ញវត្ថុវេជ្ជសាស្ត្រតាមវិធីជាច្រើនដូចជាតាមរយៈ ដោយការស្នើសុំព័ត៌មានកម្មវិធីដោយផ្ទាល់ ឬតាមទូរស័ព្ទ ឬការស្នើសុំឯកសារពាក្យសុំពីប្រភពណាមួយនៅខាងក្រោម៖

- អ្នកប្រឹក្សាហិរញ្ញវត្ថុផ្នែកវេជ្ជសាស្ត្រដែលនៅជិតនាយកដ្ឋានសេវាកម្មកិច្ចការទទួលបានរបស់អ្នកជំងឺ ឬនៅឯតុចុះឈ្មោះនៅមន្ទីរពេទ្យ Kaiser Permanente
- ទូរស័ព្ទទៅលេខ 800-813-2000
- ដោយផ្ញើរសំបុត្រ (ដោយឥតគិតថ្លៃ) ទៅ 500 NE Multnomah Street, Suite 100, Portland, OR 97232
- ដោយទាញយកពាក្យសុំតាមរយៈគេហទំព័រសហគមន៍ Kaiser Permanente នៅ kp.org/mfa/nw។

©2015 Kaiser Foundation Hospital;
Kaiser Foundation Health Plan of the Northwest

សូមប្រគល់ពាក្យសុំដែលបំពេញរួច (ដែលរួមមានព័ត៌មាននិងឯកសារដែលត្រូវបានតម្រូវទាំងអស់ ដែលបានបញ្ជាក់នៅក្នុងសេចក្តីណែនាំការដាក់ពាក្យសុំ) ទៅកាន់តុចុះឈ្មោះមន្ទីរពេទ្យ Kaiser Permanente ដែលនៅជិតបំផុត ឬផ្ញើរពាក្យសុំតាមប្រៃសណីយ៍ទៅកាន់៖ MFA Program, 500 NE Multnomah Street, Suite 100, Portland, OR 97232។

Kaiser Permanente នឹងពិនិត្យមើលពាក្យសុំដែលត្រូវបានដាក់ជូននៅពេលដែលពួកវាពេញលេញរួចរាល់ និងកំណត់ថាតើអ្នកមានសិទ្ធិទទួលបានឬទេយោងទៅលើគោលការណ៍ជំនួយហិរញ្ញវត្ថុវេជ្ជសាស្រ្ត Kaiser Permanente ។ ពាក្យសុំដែលមិនពេញលេញអាចបណ្តាលឲ្យមានការពន្យារពេលក្នុងការដំណើការ ឬបដិសេធនៃពាក្យសុំ MFA របស់អ្នកប៉ុន្តែ Kaiser Permanente នឹងផ្តល់ដំណឹងដល់បេក្ខជនហើយផ្តល់ឱកាសក្នុងការផ្ញើរឯកសារឬព័ត៌មានដែលខកខាននោះ ឲ្យបានមុនថ្ងៃផុតកំណត់ដែលត្រូវបានតម្រូវ។

©2015 Kaiser Foundation Hospital;
Kaiser Foundation Health Plan, Inc.